# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៣៣ ព.ណ.ឧ.ក.ល.ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ .-**

កែសម្រួលការកំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ ទទួលខុសត្រូវកិច្ចការទូទៅរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ២ .-**

រដ្ឋមន្ត្រី ជាប្រធានស្ថាប័នទទួលខុសត្រូវដឹកនាំការងាររួមរបស់ក្រសួងពាណិជ្ជកម្ម ជាពិសេសដឹកនាំត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម និងដោយឡែកដឹកនាំគ្រប់គ្រង៖



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- នាយកដ្ឋានបុគ្គលិក នាយកដ្ឋាននាំចេញ-នាំចូល អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ក្រុមហ៊ុនហ្គ្រីនត្រេដ ទីប្រឹក្សា ឬអនុព័ន្ធពាណិជ្ជកម្មក្រៅប្រទេស និងតំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស
- ពិនិត្យតាមដានរាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រធានក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម។

**ប្រការ៣** .-

ត្រូវបានបែងចែកភារកិច្ចជូន រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ ដើម្បីជួយការងាររដ្ឋមន្ត្រី ដូចខាងក្រោម៖

១. ឯកឧត្តម **គឹម ស៊ីថន** និងឯកឧត្តម **សុខ សុភ័ក្រ្ត** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖
- នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់
- មន្ទីរពាណិជ្ជកម្មខេត្តកោះកុង មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ មន្ទីរពាណិជ្ជកម្មខេត្តកំពត
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (C/O) នាំចេញទៅអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- កិច្ចសហប្រតិបត្តិការតំបន់ និងអនុតំបន់៖ តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម តំបន់មរតកកម្ពុជា-ឡាវ-ថៃ
- ក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំផែនការមេតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-វៀតណាម ដល់ឆ្នាំ២០៣០
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាជាតិកសុភាកម្ម
- ពាណិជ្ជកម្មអន្តរជាតិ៖ ពាណិជ្ជកម្មទ្វេភាគី ពហុភាគី ពាណិជ្ជកម្មកម្ពុជា-សហគមន៍អឺរ៉ុប និងអង្គការពាណិជ្ជកម្មពិភពលោក
- ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម
- សហព័ន្ធស្រូវអង្ករកម្ពុជា
- គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- គណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល
- ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម
- សមាជិកក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិត្យសភាកម្ពុជា។

២. ឯកឧត្តម **ឱក ម៉ុច** និងឯកឧត្តម **រាជ រ៉ា** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖
- វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ និងនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (C/O) នាំចេញទ្វីបទៅអាមេរិក
- ពិនិត្យតាមដានផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ
- គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ក្រុមការងារសេកម្មភាពជនពិការ
- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ
- ក្រុមការងារផ្នែកអប់រំ។

៣. ឯកឧត្តម **ម៉ៅ ថូរ៉ា** ឯកឧត្តម **សុខ សុភ័ក្ត្រ** និងឯកឧត្តម **ម្ចូន សារៈមុនី** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖

- នាយកដ្ឋាននីតិកម្ម និងនាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន
- មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ មន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងព័ត៌មាន និងក្រសួងយុត្តិធម៌
- សភាពាណិជ្ជកម្មកម្ពុជា
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ក្រុមការងារផ្នែកស្រូវ-អង្ករ
- ក្រុមការងាររៀបចំសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថលកម្ពុជា
- ក្រុមការងាររៀបចំសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល។

៤. ឯកឧត្តម **ឈួន ដារ៉ា** និងឯកឧត្តម **សំ សិរីរតន៍** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖

- នាយកដ្ឋានកិច្ចការពិព័រណ៍ និងនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល មន្ទីរពាណិជ្ជកម្មខេត្តតាកែវ មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ
- គណៈកម្មាធិការរៀបចំផែនការ កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសូត្រ និងផ្លូវសូត្រសមុទ្រសតវត្សទី២១
- ក្រុមការងារផ្នែកទេសចរណ៍
- ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម។

៥. ឯកឧត្តម **អ៊ុក ប្រជា** និងឯកឧត្តម **ភឹម សុខុន** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖

- នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ មន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងរ៉ែ និងថាមពល និងក្រសួងបរិស្ថាន
- ក្រុមប្រឹក្សាជាតិកម្មសិទ្ធិបញ្ញា
- ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច មធ្យម
- ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា
- ក្រុមការងារផ្នែកថាមពល និងធនធានរ៉ែ
- ក្រុមប្រឹក្សាជាតិកាយរឹទ្ធិកម្ពុជាសម្រាប់អាណត្តិទី៣
- សមាជិកលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍។

៦. លោកជំទាវ **តឹករ៉េត កំរេខ** និងលោកជំទាវ **ចម និម្មល** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖

- នាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានអាមេរិក
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (C/O) នាំចេញទៅអាស៊ីប៉ាស៊ីហ្វិក
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប និងមន្ទីរពាណិជ្ជកម្មខេត្តកែប

- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងកិច្ចការនារី
- គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU)
- ក្រុមការងារកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក (TIFA)
- គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ក្រុមការងារផ្នែកសុខាភិបាល
- គណៈកម្មការអន្តរក្រសួងរៀបចំទិវាវប្បធម៌ជាតិ ៣មីនា
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

៧. ឯកឧត្តម **ម៉េង សុធី** និងឯកឧត្តម **សាន់ សារ៉ន** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ៖
- នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- មន្ទីរពាណិជ្ជកម្មខេត្តរតនគិរី និងមន្ទីរពាណិជ្ជកម្មខេត្តមណ្ឌលគិរី
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងការពារជាតិ ក្រសួងផែនការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អង្គភាពប្រឆាំងអំពើពុករលួយ
- សម្របសម្រួលការងារសភាពាណិជ្ជកម្មកម្ពុជា
- ក្រុមការងារសម្របសម្រួលការងារគ្រប់គ្រងគ្រោះមហន្តរាយ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាជាតិស្ថិតិ
- សម្របសម្រួលការងារជាមួយគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច
- ក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ។

៨. ឯកឧត្តម **ឃឹម សិរីវឌ្ឍ** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានរដ្ឋបាល
- មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ និងមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមុខងារសាធារណៈ
- ប្រធានក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួងពាណិជ្ជកម្ម
- ប្រធានក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ
- ពិនិត្យ និងតាមដានការអនុវត្តក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន រាជធានី-ខេត្ត
- ក្រុមការងារផ្នែកសំណង់ និងអចលនទ្រព្យ
- ក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- សមាសភាពនៃក្រុមប្រឹក្សាបណ្ណសារ។

៩. ឯកឧត្តម **ប៉ាច ហេងតារា** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- មន្ទីរពាណិជ្ជកម្មខេត្តពោធិ៍សាត់ មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង និងមន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន

- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងធម្មការ និងសាសនា និងធនាគារជាតិនៃកម្ពុជា
- ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ។

១០. ឯកឧត្តម **ស៊ុន ដារ៉ាវឌ្ឍ** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារៈ

- ទទួលបន្ទុកជានាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារក្នុងក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត។

១១. ឯកឧត្តម **ម៉ក់ ពេជ្ររិទ្ធ** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារៈ

- ផ្តល់យោបល់ ជូនរដ្ឋមន្ត្រី ក្នុងកិច្ចការជួយពង្រឹងបទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ឲ្យបានប្រសើរ ក្នុងវិស័យកិច្ចការពារអ្នកប្រើប្រាស់ ការប្រកួតប្រជែងឲ្យមានសមភាព និងសុវត្ថិភាពម្ហូបអាហារ
- ទទួលភារកិច្ចដឹកនាំកិច្ចប្រជុំ រៀបចំបទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- ទទួលភារកិច្ចដឹកនាំកិច្ចប្រជុំ ជំរុញសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង និងសេចក្តីព្រាងច្បាប់ស្តីពីម្ហូបអាហារ ឲ្យបានចប់ជាស្ថាពរ និងរៀបចំបទប្បញ្ញត្តិសម្រាប់អនុវត្តជាបន្ត
- សម្របសម្រួលជាមួយ អគ្គនាយកដ្ឋាន ការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- ដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំត្រីមាស ប្រចាំឆមាស របស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង
- គណៈកម្មាធិការកូដិចកម្ពុជា
- គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន
- អាជ្ញាធរជាតិអាវុធគីមី។

**ប្រការ៤ .-**

ត្រូវបានបែងចែកភារកិច្ចជូនអនុរដ្ឋលេខាធិការ ដូចខាងក្រោមៈ

១- ឯកឧត្តម **ពេជ ឫទ្ធី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **គឹម ស៊ីថន** និងលោកជំទាវ **តឹករ៉េត ភំរេខ**

២- លោកជំទាវ **សូ ស្រីមុិច** ទទួលភារកិច្ចជួយការងារ លោកជំទាវ **តឹករ៉េត ភំរេខ** និង ឯកឧត្តម **ឃឹម សិរីវឌ្ឍ**

៣- ឯកឧត្តម **ចាន់ រ៉ាស៊ី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឱក ម៉ុខ** និងឯកឧត្តម **ម៉ៅ ថូរ៉ា** និងមានភារកិច្ចជួយការងារពាក់ព័ន្ធៈ

- ក្រុមការងារអន្តរក្រសួងទទួលបន្ទុកកិច្ចការ សរសេររបាយការណ៍ជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជូនអង្គការសហប្រជាជាតិ
- គណៈកម្មការអន្តរក្រសួងសម្រាប់គ្រប់គ្រងសកម្មភាពការងារអង្គការមិនមែនរដ្ឋាភិបាលបរទេស។

៤- ឯកឧត្តម **ម៉ក់ ឧសភា** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឱក ម៉ុខ** និង លោកជំទាវ **ចម និម្មល**

៥- ឯកឧត្តម **សំហេង បូរ៉ា** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **អ៊ុក ប្រជា** និង លោកជំទាវ **ចម និម្មល**

៦- ឯកឧត្តម **ឡស់ រ៉ូហ្សាក់** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឈួន ដារ៉ា** និង ឯកឧត្តម **សាន់ សារ៉ែន**

៧- ឯកឧត្តម **ម៉ុន ចន្ធី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **សុខ សុភ័ក្ត្រ** និង ឯកឧត្តម **ប៉ាច ហេងតារា** និងមានភារកិច្ចជួយការងារពាក់ព័ន្ធ៖

- ក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីលទ្ធភាពបង្កើតច្រកទ្វារអ៊ីនធើណេតតែមួយ (National Internet Gateway)
- ក្រុមការងារអន្តរក្រសួង សិក្សា រៀបចំ និងពិនិត្យលទ្ធភាពកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិ ( National Payment Gateway )

៨- ឯកឧត្តម **ស៊ឹម សុខខេង** ឯកឧត្តម **ប៉ែន សុទិដ្ឋាតិ** ទទួលភារកិច្ចជួយការងារ លោកជំទាវ **តឹករ៉េត កំរេខ** និង ឯកឧត្តម **សុខ សុភ័ក្ត្រ** និងមានភារកិច្ចជួយការងារពាក់ព័ន្ធ៖

- តំណាងក្រសួងដើម្បីចូលរួមប្រជុំវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែ។

៩- ឯកឧត្តម **ស៊ាង ថៃ** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឈួន ដារ៉ា** និងឯកឧត្តម **សំ សិរីរតន៍**

១០- ឯកឧត្តម **ថៅ សុខមុនី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឱក ម៉ុង** និងឯកឧត្តម **ម៉ៅ ថូរ៉ា**

១១- លោកជំទាវ **ម៉ុន ណារ៉ាត** ទទួលភារកិច្ចជួយការងារ លោកជំទាវ **តឹករ៉េត កំរេខ** និងលោកជំទាវ **ចម និម្មល**

១២- ឯកឧត្តម **ចាន់ ហ៊ីង** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ម៉េង សុធី** និងឯកឧត្តម **ឃឹម សិរីវឌ្ឍ**

១៣- ឯកឧត្តម **គឹម មាសសុខសីហា** ឯកឧត្តម **ស៊ុំ ណារុន** និងឯកឧត្តម **លឿង រដ្ឋា** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ម៉ក់ ពេជ្ជរិទ្ធ**

១៤- ឯកឧត្តម **គឹម មាសសុខសីហា** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ម៉ៅ ថូរ៉ា** ឯកឧត្តម **សុខ សុភ័ក្ត្រ** និងឯកឧត្តម **មួន សារៈមុនី**។

**ប្រការ៥** .-

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មានភារកិច្ចអនុវត្តការងារផ្សេងទៀត តាមការចាំបាច់ដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៦** .-

**ការកំណត់របៀបរបបការងារ៖**

១- រដ្ឋមន្ត្រី ពិនិត្យសម្រេច និងចុះហត្ថលេខាលើរាល់ឯកសារមានដូចជា៖ ប្រកាស សេចក្ដីសម្រេច សារាចរ សេចក្ដីណែនាំ បង្គាប់ការ និងឯកសារដែលត្រូវផ្ញើជូនប្រមុខរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ឬស្ថាប័នកំពូលផ្សេងទៀត។

២- ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ទទួលខុសត្រូវ និងពិនិត្យការងារទទួលបន្ទុកដែលបានប្រគល់ជូន និងផ្ដល់យោបល់ជូនរដ្ឋមន្ត្រី ពិនិត្យ សម្រេចលើរាល់សំណើដែលមានការពាក់ព័ន្ធ។

៣- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ ត្រូវទទួលខុសត្រូវ និងពិនិត្យផ្ដល់យោបល់ជូនរដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ នូវការងារដែលស្ថិតនៅក្នុងចង្កោម ការងាររបស់ខ្លួន។

**ប្រការ៧** .-

**ការកំណត់របបប្រជុំ៖**

ក- <u>ប្រជុំប្រចាំខែ៖</u>

រៀងរាល់ថ្ងៃពុធ សប្ដាហ៍ទីបួននៃខែនីមួយៗ ឬតាមការចាំបាច់ ដោយមានការចូលរួមពីរដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង អគ្គនាយកក្រុមហ៊ុនប្រៃសណីយ៍ ប្រធាន អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីស្ដាប់របាយការណ៍ ពិនិត្យដោះស្រាយ និងកែលម្អចំណុចខ្វះខាត។

**ខ- ប្រជុំថ្នាក់អគ្គនាយកដ្ឋាន៖**

រៀងរាល់ខែនីមួយៗ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងក្រុមហ៊ុនហ្វ្រីនត្រេដ ត្រូវរៀបចំប្រជុំប្រចាំខែ ដើម្បីបូកសរុបអំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ លើកវិធានការដោះស្រាយ និងកំណត់ទិសដៅការងារដែលត្រូវធ្វើបន្ត។

**គ- ប្រជុំថ្នាក់នាយកដ្ឋាន៖**

រៀងរាល់ពីរសប្តាហ៍ម្តង នាយកដ្ឋានត្រូវរៀបចំប្រជុំផ្ទៃក្នុងនាយកដ្ឋានរបស់ខ្លួននីមួយៗ ដើម្បីពិនិត្យតាមដានការងាររបស់អង្គភាព។

**ឃ- ប្រជុំថ្នាក់មន្ទីរពាណិជ្ជកម្ម៖**

រៀងរាល់ខែនីមួយៗ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវរៀបចំប្រជុំផ្ទៃក្នុងដើម្បីពិនិត្យតាមដានការងាររបស់មន្ទីរ។

**ង-** រាល់កិច្ចប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុអង្គប្រជុំ។

**ប្រការ៨ ._**

ប្រកាសលេខ២០០ ព.ណ.ខកល.ប្រក ស្តីពីការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៩ ._**

នាយកខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ដែលមានឈ្មោះក្នុងប្រការ៣ និងប្រការ៤ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- ឯកសារ កាលប្បវត្តិ